# ការសំភាសន៍របស់ម៉ាក់យាយ អ៊ុន ទី

កៈ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ាវ ខៈ អ្នកដែរអោយសំភាសន៍ ម៉ាក់យាយ អ៊ុន ទី

## <u>ការសង្ខេបប្រវត្តិរបស់ម៉ាក់យាយ អ៊ុន ទី</u>

ម៉ាក់យាយ អ៊ុន ទី មានអាយុ74ឆ្នាំ នៅឆ្នាំ2018 ម៉ាក់យាយ អ៊ុន ទី មានភេទស្រី ម៉ាក់យាយ អ៊ុន ទី មានទីលំនៅបច្ចុប្បន្ននៅភូមិ5 សង្កាត់ផ្សារថើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នមពេញ។

កៈ
ចឹងជាដំបូងខ្ញុំអរគុណម៉ាក់យាយដែរបានអោយខ្ញុំបានសំភាសន៍បីប្រវត្តិរបស់ម៉ាក់យាយ ហើយការសំភាសន៍នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថា BYU ហាសម៉ាក់យាយ
ដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រត្តិឪពុកម្ដាយ នឹងប្រវត្តិរបស់ដូនតា ហើយនៅពេលដែរខ្ញុំសំភាសន៍ម៉ាក់យាយហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu
ចឹងហាសម៉ាក់យាយ
ចឹងនៅពេលដែរខ្ញុំសំភាសន៍ម៉ាក់យាយនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយ ចឹងសំរាប់ម៉ាក់យាយយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ពីម៉ាក់យាយនឹងទៅក្នុងវេសាយសាលាដែរទេ?

ខៈ យល់ព្រមតើ

កៈ បាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍ម៉ាក់យាយមានឈ្មោះថា ជាង ស៊ីអ៊ាវ ហើយការសំភាសន៍នេះធ្វើនៅថ្ងៃទី8 ខែ2 ឆ្នាំ 2018 ហើយធ្វើភូមិ5 ហីបង?

ខៈ ចា៎!ភូមិ

កៈ នៅភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ ចឹង សំរាប់ម៉ាក់យាយមានឈ្មោះពេញឈ្មោះអីគេដែរម៉ាក់យាយ?

ខ៖  ខ្ញុំឈ្មោះ អ៊ុន ទី

ក៖  ចុះមានឈ្មោះហៅក្រៅទេម៉ាក់យាយ?

ខ៖  អត់មានទេ

ក៖  ចុះកាលពីក្មេងមាននរណាគេហៅម៉ាក់យាយឈ្មោះអីផ្សេងទេ?

ខ៖  អត់មានទេ

ក៖  ចុះម៉ាក់យាយសព្វថ្ងៃនឹងម៉ាក់យាយអាយុប៉ុន្មានដែរម៉ាក់យាយ?

ខ៖  ខ្ញុំអាយុ74ឆ្នាំ

ក៖  ចុះម៉ាក់យាយមានដឹងថាម៉ាក់យាយកើតនៅថ្ងៃខែឆ្នាំណាទេម៉ាក់យាយ?

ខ៖  កើតនៅខែ4

ក៖  ចុះឆ្នាំវិញម៉ាក់?

ខ៖  ឆ្នាំខ្ញុំភ្លេចបាត់ហើយនឹង ខ្ញុំអត់ចាំទេ

ក៖  ចឹងម៉ាក់យាយកើតនៅឆ្នាំ1944ម៉ាក់

ខ៖  ចា៎!នឹងហើយ

ក៖  ចុះឆ្នាំច័ន្ទគតិម៉ាក់យាយឆ្នាំអីគេដែរម៉ាក់យាយ ឆ្នាំជូត ឆ្លូវ ខាល ថោះហាស ម៉ាក់យាយឆ្នាំអីគេដែរម៉ាក់?

ខ៖  ខ្ញុំឆ្នាំរកា

ក៖  ចុះម៉ាក់យាយកើតនៅភូមិអី ឃុំអី ស្រុកអី ខេត្តអីម៉ាក់យាយមានចងចាំទេ?

ខ៖  នៅខេត្តពោសាត់

ក៖  អូ៎!នៅខេត្តពោសាត់ ប៉ុន្តែនៅភូមិអី ឃុំអីម៉ាក់យាយ?

ខ៖  នៅស្រុកគគរ

ក៖  នៅស្រុកគគរ ចុះនៅភូមិអីដែរម៉ាក់យាយ?

ខ៖  បឹងកន្ទួត ឃុំកំពុងគរ ភូមិបឹងកន្ទួត ស្រុកគគរ ខេត្តពោសាត់

ក៖  ចុះម៉ាក់យាយមានបងប្អូនចំនួនប៉ុន្មាននាក់ដែរម៉ាក់យាយ?

ខ៖  ខ្ញុំមានបងប្អូនច្រើនដែរប៉ុន្តែស្លាប់បាត់អស់ទៅណាស់
នៅសល់តែចុះម៉ាក់យាយកើតនៅភូមិអី ឃុំអី ស្រុកអី ខេត្តអីម៉ាក់យាយមានចងចាំទេ?

ខ៖  នៅខេត្តពោសាត់

ក៖  អូ៎!នៅខេត្តពោសាត់ ប៉ុន្តែនៅភូមិអី ឃុំអីម៉ាក់យាយ?

ខ៖  នៅស្រុកគគរ

ក៖  នៅស្រុកគគរ ចុះនៅភូមិអីដែរម៉ាក់យាយ?

ខ៖  បឹងកន្ទួត ឃុំកំពុងគរ ភូមិបឹងកន្ទួត ស្រុកគគរ ខេត្តពោសាត់

ក៖  ចុះម៉ាក់យាយមានបងប្អូនចំនួនប៉ុន្មាននាក់ដែរម៉ាក់យាយ?

ខ៖  ខ្ញុំមានបងប្អូនច្រើនដែរប៉ុន្តែស្លាប់បាត់អស់ទៅណាស់ នៅសល់តែ3នាក់ទេ

ក៖  មាន3នាក់ណោះម៉ាក់យាយ ប៉ុន្តែម៉ាក់យាយមានចងចាំឈ្មោះពួកគាត់ដែរទេ?

ខ៖  រាប់អ្នកស្លាប់មែន?

ក៖  អត់ទេទាំងអ្នកនៅរស់ហាស?

ខ៖  អ្នកនៅរស់នឹងមែន?

ក៖  ឈ្មោះពួកគាត់មានឈ្មោះអីគេខ្លះដែរម៉ាក់យាយ?

ខ៖  ឈ្មោះ សុង ហ៊ាង ហើយឈ្មោះ សុងហេង

ក៖  ហើយបន្ទាប់មកបានម៉ាក់យាយ?

ខ៖  ខ្ញុំបងតា

ក៖  អូ៎!ម៉ាក់យាយបងគេហោស?

ខ៖  ចា៎!ខ្ញុំបងគេតា

កៈ ចុះម៉ាក់យាយធ្លាប់មានអនុស្សាវរីយ៍អីកាលពីនៅក្មេងៗអី ប៉ុនអូនហាស ដូចជាម៉ាក់យាយធ្វើអីគេដែរ?

ខៈ ខ្ញុំទៅតែស្រែ នឹងឃ្វាលតែគោនឹង ឃ្វាលក្របីនឹង

កៈ លក្ខណះថាលេងឡឹកបាយឡ រីមួយក៏លេងចុយអីចឹងហាសមានអត់ម៉ាក់យាយ?

ខៈ លេងចេះតែលេងហើយតែវាមិនអាចចាំបានទេ កាលនៅតូចៗល្មមអាយុ7-8ឆ្នាំនឹងទៅឃ្វាលគោហើយនឹង

កៈ
ចុះម៉ាក់យាយគិតថាកាលពីក្មេងម៉ាក់យាយចូលចិត្តលេងអីជាមួយពួកគាត់ដែរម៉ាក់យាយ?

ខៈ ដូចជាមិនដែរបានលេងអីផង លេងតែបិទពួនអីនឹងហាស

កៈ អូ៎!លេងបិទពួនហោសម៉ាក់យាយ?

ខៈ កាលពីក្មេងៗនឹងហាស

កៈ ប៉ុន្តែធ្លាប់ទៅស្រែអីជាមួយពួកគាត់ដែរទេ?

ខៈ ធ្លាប់ទៅតា

កៈ ចុះម៉ាក់យាយទៅនឹងធ្លាប់ធ្វើអីគេខ្លះទៅជាមួយបងប្អូនរបស់ម៉ាក់យាយហោស?

ខៈ ទៅនឹងទៅតែស្រែនឹងហាសទៅស្ទូង ទៅដក ខែច្រូតទៅទៅច្រូតទៅណាស់

កៈ បាទម៉ាក់យាយ ចុះបងប្អូនរបស់ម៉ាក់យាយសព្វថ្ងៃគាត់រស់នៅណាដែរម៉ាក់យាយ?

ខៈ គាត់នៅតីក្រុងភ្នំពេញនឹងតា

កៈ ចុះពួកកាត់ធ្វើអីគេដែរម៉ាក់យាយ?

ខៈ គាត់ក៏រកស៊ីធម្មតា លក់ដូរដែរនឹងហាស

កៈ អូ៎!លក់ដូរដែរហោសម៉ាក់ ទាំងពីរនាក់នឹងហោសម៉ាក់យាយ?

ខៈ ចា៎!នឹងហើយ

កៈ ចុះឪពុករបស់ម៉ាក់យាយគាត់មានឈ្មោះអីគេដែរម៉ាក់យាយ?

ខ៖  សឹង អ៊ុន

ក៖  ចុះគាត់អាយុប៉ុន្មានដែរសព្វថ្ងៃនឹងម៉ាក់យាយ?

ខ៖  គាត់ស្លាប់បាត់ហើយនឹង

ក៖  ប៉ុន្តែដូចជាគាត់អាយុប៉ុន្មានដែរពេលដែរគាត់ស្លាប់នឹងម៉ាក់យាយ?

ខ៖  គាត់អាយុប៉ែតជាង ហើយដល់កៅហើយនឹងហាស

ក៖  ដល់ឥឡូវនឹងហោសម៉ាក់យាយ?

ខ៖  ដោយសារតែគាត់ស្លាប់យូរដែរហើយនឹងហាស

ក៖  ចុះម៉ាក់យាយមានដឹងថាគាត់កើតនៅណាដែរទេម៉ាក់យាយ?

ខ៖  គាត់កើតនៅភូមិជាមួយគ្នានឹង

ក៖  គាត់នៅខេត្តពោសាត់នឹងហោសម៉ាក់យាយ?

ខ៖  ចាំ!នៅណុង

ក៖  ចុះម្តាយរបស់ម៉ាក់យាយគាត់មានឈ្មោះអីគេដែរម៉ាក់យាយ?

ខ៖  គាត់ឈ្មោះ យឹម ហ៊ាប

ក៖  ចុះគាត់អាយុប៉ុន្មានដែរម៉ាក់យាយមានចងចាំទេ?

ខ៖  កាលពីគាត់ស្លាប់នឹងអាយុ86ឆ្នាំហើយនឹង ប៉ុន្មានទេនេះ

ក៖  អូ៎!ម៉ាក់យាយភ្លេចហើយ?

ខ៖  គាត់ស្លាប់នៅអាយុ88ឆ្នាំ គាត់ស្លាប់អស់10ឆ្នាំហើយនឹងហាស

ក៖  អូ៎!អស់10ឆ្នាំណាម៉ាក់យាយ ចុះគាត់កើតនៅណាម៉ាក់យាយមានដឹងទេ?

ខ៖  នៅស្រុកភូមិកំណើតតែមួយនឹងហាស

កៈ អូ!បាទម៉ាក់យាយ
ចុះឪពុករបស់ម៉ាក់យាយគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរម៉ាក់យាយ
កាលពីគាត់នៅក្មេងហាស?

ខៈ គាត់ដកស្ទូងដូចគ្នានឹងហាស

កៈ អូ!គាត់ដក់ស្ទូង ដែរហោស?

ខៈ នឹងហើយគាត់ធ្វើតែស្រែនឹងហាស

កៈ ចុះឪពុករបស់ម៉ាក់យាយដូចជាគាត់ស្លូត រឺមួយក៏កាចដែរម៉ាក់យាយ?

ខៈ គាត់មិនកាចទេនឹង

កៈ អូ!គាត់ស្លូតហោសម៉ាក់យាយ
ចុះម្តាយរបស់ម៉ាក់យាយគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរម៉ាក់យាយ?

ខៈ គាត់ជាមេចង្រ្កាននឹង

កៈ ចឹងគាត់នៅតែផ្ទះទេណម៉ាក់យាយ?

ខៈ នឹងហើយគាត់នៅតែផ្ទះទេ

កៈ ចុះគាត់ស្លូត រឺមួយក៏កាចដែរម៉ាក់យាយ?

ខៈ គាត់មិនកាចទេម៉ែឪរបស់ខ្ញុំកាត់ស្លូតណាស់

កៈ ចុះពេលដែរម៉ាក់យាយ នៅជាមួយឪពុកម្តាយហាស
តើម៉ាក់យាយមានធ្លាប់ចងចាំអនុស្សាវរីយ៍អីជាមួយគ្នាដែរទេ?

ខៈ អត់ដែរដឹងផង អត់មានទេ

កៈ ដូចជាធ្លាប់ទៅស្រែ រឺមួយធ្វើម្ហូបអីជាមួយគ្នាចឹងហាស រឺធ្លាប់ធ្វើអីជាមួយគ្នាចឹងហាស?

ខៈ ធ្វើចេះតែធ្វើហើយនឹង មានការដាំស្លម្នាក់ជួយធ្វើនេះ ម្នាក់ជួយធ្វើនោះ
ឆាប់បានញុំាចឹងហាស

កៈ ចុះឪពុកម្ដាយរបស់ម៉ាក់យាយគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់ពួកគាត់កាលពីនៅក្មេងៗទៅម៉ាក់យាយទេ?

ខៈ អត់មានទេ

កៈ អត់ដែរទេណា ថាកាលពីពួកគាត់នៅក្រមុំនឹងនៅកំលោះពួកកាត់ធ្វើអីគេខ្លះដែរចឹងហាស?

ខៈ អត់មានដឹងអីទេ

កៈ អូ៎!បាទ ចុះយាយតាខាងឪពុកម៉ាក់យាយមានស្គាល់ឈ្មោះគាត់ដែរទេម៉ាក់យាយ?

ខៈ ភ្លេចអស់ហើយអូនអើយមិនបានស្គាល់ទេនឹង ដូចជាគាត់ស្លាប់បាត់យូរដែរៗហើយ

កៈ ចុះយាយតាខាងម្ដាយម៉ាក់យាយអត់ចាំឈ្មោះគាត់ដែរ?

ខៈ គាត់ស្លាប់យូរដែរហើយ

កៈ ចុះគាត់កើតនៅណាម៉ាក់យាយអត់ដឹងទេ?

ខៈ គាត់កើតនៅនឹង គាត់កើតនៅខេត្តពោសាត់នឹងទាំងអស់នឹងហាសអត់មានទៅណាមកណាអីទេនឹងហាស

កៈ ចុះម៉ាក់យាយមកនៅទីក្រុងភ្នំពេញនឹងយូរនៅម៉ាក់យាយ?

ខៈ មកនៅឆ្នាំ1979នឹង

កៈ មកនៅឆ្នាំ1979ហោសអូប្រហែលជាឥឡូវនឹងចូលប្រហែលជាជិត40ឆ្នាំហើយណាម៉ាក់យាយ?

ខៈ នឹងហើយប៉ុណ្ណឹង

កៈ ចុះម៉ាក់យាយមានបងប្អូន រឺមួយក៏កូនចៅណាដែររស់នៅក្រៅប្រទេសទេដែរក្រៅពីស្រុកខ្មែរហាសម៉ាក់យាយ?

ខៈ អត់មានផង មានក្មួយ

កៈ មានក្មួយហោសបង គាត់នៅណាវិញទៅ?

ខ៖ គាត់នៅអាមេរិច នៅកាលីហ្វ័រញ៉ា

ក៖ អូ៎!គាត់នៅកាលីហ្វ័រញ៉ាហោស ចុះគាត់ធ្វើអីគេដែរនៅណុងហោសម៉ាក់យាយ?

ខ៖ គាត់ជាអ្នករកស៊ីដូចតែគ្នាចឹងហាស

ក៖ ចុះម៉ាក់យាយមានចងចាំឈ្មោះប្តីរបស់ម៉ាក់យាយ ថាគាត់មានឈ្មោះអីគេដែរទេ?

ខ៖ ស្វាមីរបស់ខ្ញុំហោស ឈ្មោះអ៊ុក ស៊ុ ថន

ក៖ ចុះម៉ាក់យាយមានចងចាំថ្ងៃខែ
ដែរម៉ាក់យាយរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាចឹងហាសម៉ាក់យាយ?

ខ៖ អត់ចងចាំទេ

ក៖ ប៉ុន្តែកូនរបស់ម៉ាក់យាយសព្វថ្ងៃគាត់អាយុប៉ុន្មានដែរម៉ាក់យាយ កូនបងគេហាស?

ខ៖ កូនបងអាយុសែប៉ុន្មានទេមីមុំអាយុ40ឆ្នាំហី?

ក៖ អាយុ40ឆ្នាំហោសម៉ាក់យាយ?

ខ៖ អាយុ43ឆ្នាំហើយនឹង

ក៖ ចឹងមានន័យថាម៉ាក់យាយការអស់រយះពេលសែសិបឆ្នាំជាងហើយណាម៉ាក់យាយ?

ខ៖ នឹងហើយចាំ!កូនរបស់ខ្ញុំអាយុជាង50ឆ្នាំហើយមួយៗនឹង

ក៖ អូ៎!ជាង50ឆ្នាំហើយចឹងមានន័យថាម៉ាក់យាយការអស់ជាង50ឆ្នាំហើយនឹង?

ខ៖ ប្រហែលជាប៉ុណ្ណឹង

ក៖ ចុះពេលដែរម៉ាក់យាយរៀបចំអាពាហ៍ពិពាហ៍នឹងគិតថា
ឪពុកម្តាយរបស់ម៉ាក់យាយជាអ្នករៀបចំអោយ
រឺមួយក៏ម៉ាក់យាយជាអ្នករៀបដោយខ្លួនឯងដែរម៉ាក់យាយ?

ខ៖ ម៉ែឪជាអ្នករៀបចំអោយ

ក៖ ប៉ុន្តែមានជាថ្លៃបណ្ណាការទេម៉ាក់យាយ?

ខ៖ ខ្ញុំអត់ដឹងដែរនឹងហាស

ក៖ អ្ហូ!ម៉ាក់យាយអត់ដឹងទេណាម៉ាក់យាយ?

ខ៖ ពីព្រោះចាស់ៗគេជាអ្នករៀបចំអោយនឹង

ក៖ ម៉ាក់យាយអាចប្រាប់ខ្ញុំបានទេ ដូចជាម៉ាក់យាយស្គាល់តា ដំបូងនៅពេលណាដែរ ហើយហេតុអីបានតាស្រលាញ់ម៉ាក់យាយចឹងហាស?

ខ៖ អត់ដែរស្គាល់ទេ ចាស់ៗរៀបអោយតែម្តងនឹង ក៏យកទៅនឹងហាស

ក៖ ចឹងមានន័យថាអត់ដឹងថាអស់រយះពេលប៉ុន្មានដែរតា ស្រលាញ់ម៉ាក់យាយទេ?

ខ៖ អត់ដឹងទេ ដល់ពេលដែរចាស់ៗការអោយហើយក៏ការទៅនឹងហាស បើមិនចង់ការក៏អត់ទៅ ចាស់ពីដើមចឹងហាសអូន

ក៖ បាទម៉ាក់យាយ ចុះម៉ាក់យាយធ្លាប់បានរៀនភាសាខ្មែរទេ?

ខ៖ រៀនភាសាខ្មែរ?

ក៖ រៀនអក្សរហាស?

ខ៖ អត់ចេះទេ

ក៖ អត់ដែរបានចូលរៀនទេហោស?

ខ៖ អត់មានចេះទេ ចាស់ពីដើមអត់មានទេ

ក៖ ចុះម៉ាក់យាយមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេចឹង?

ខ៖ អត់មានទេ ចេះតែភាសាខ្មែរនឹង

ក៖ វៀតណាម ថៃអី អត់មានចេះទេណាម៉ាក់យាយ?

ខ៖ អត់ចេះទេ

ក៖ ចុះម៉ាក់យាយធ្លាប់មានមិត្តភក្តិស្និទ្ធស្នាលដែរធំធាត់មកជាមួយគ្នាដែរទេ?

ខ៖ អត់មានទេ

ក៖ អត់ដែរមានដែរហោសម៉ាក់យាយ?

ខ៖ អត់ដែរមានទេ គ្រាន់តែស្គាល់គ្នាធម្មតាទេ អត់ចេះមានមិត្តភក្តិទេ ក្មេងពីដើមនឹង

ក៖ ចុះម៉ាក់យាយគិតថាម៉ាក់យាយធ្លាប់ធ្វើការងារអីគេខ្លះតាំងពីក្មេងហាស
រហូតមកដល់ពេលនេះហាសម៉ាក់យាយធ្លាប់ធ្វើការងារអីគេខ្លះដែរ
រឺក៏ធ្លាប់រកស៊ីអីគេខ្លះដែរចឹងហាស?

ខ៖ អត់ទេនៅតែធ្វើតែស្រែនឹង

ក៖ ចុះធ្វើតែស្រែទេណាម៉ាក់យាយ?

ខ៖ ចេះធ្វើតែស្រែនឹង

ក៖ ចុះម៉ាក់យាយធ្លាប់មានលក់ដូរ រឺបើកអាជីវកម្មអីទេ?

ខ៖ អត់ទេ

ក៖ អត់ទេណាម៉ាក់យាយ ចុះម៉ាក់យាយធ្លាប់ចិញ្ចឹមសត្វមាន់ ទា ជ្រូក
គោអីម៉ាក់យាយធ្លាប់ចិញ្ចឹមទេ?

ខ៖ អ៊ូ!ជ្រូកគោអីមានច្រើនណាស់

ក៖ កាលពីចិញ្ចឹមនឹងចិញ្ចឹមនៅស្រុកហោសម៉ាក់យាយ?

ខ៖ ចាំ!ចិញ្ចឹមពីក្មេង ម៉ែឪបានចិញ្ចឹមពីក្មេងនឹង

ក៖ ចុះចិញ្ចឹមជាគ្រួសាររឺមួយក៏ចិញ្ចឹមជាលក្ខណះកសិដ្ឋានដែរម៉ាក់យាយ?

ខ៖ ទេចិញ្ចឹមមួយពីរនឹង

ក៖ អូបាទម៉ាក់យាយ!
ចុះម៉ាក់យាយគិតថាជីវិតរបស់ម៉ាក់យាយមានការផ្លាស់ប្តូរអីគេខ្លះដែរម៉ាក់យាយសំរាប់តាំ
ងពីក្មេងរហូតមកដល់ពេលនេះហាស មានការផ្លាស់ប្តូរអីគេខ្លះដែរទៅ?

ខ៖ ពីក្មេងមកដល់ពេលនេះនឹង ចេះតែភ្លេចខ្លះដែរនឹង ខ្លះវង្វេងចឹងទៅ
ចុះបើចាស់ហើយអូនអើយ

ក៖ ចុះម៉ាក់យាយចូលចិត្តពិសារម្ហូបអីគេដែរម៉ាក់យាយ?

ខ៖  ធម្មតាម្ហូបអីក៏បានដែរ

ក៖  លក្ខណះស្ងោរ ឆាហាសម៉ាក់យាយ?

ខ៖  ប្រហុក ផ្អក

ក៖  ប្រហុក ផ្អកហោសម៉ាក់យាយ?

ខ៖  ត្រីងៀត ស្ងោរ ឆា

ក៖  កកូរ ការីអីនឹងហោស?

ខ៖  កកូរ ការីអីចេះទាំងអស់នឹង

ក៖  ប៉ុន្តែម៉ាក់យាយគិតថា ម្ហូបអីដែរម៉ាក់យាយនៅតែចងចាំហាស
ហើយនឹងចង់ហូបចឹងហាសម៉ាក់យាយ?

ខ៖  អត់មានទេ

ក៖  អត់មានទេហោស

ខ៖  មានអីហូបនឹង

ក៖  ចុះម៉ាក់យាយគិតថាល្បែងប្រជាប្រិយ៍អីដែរម៉ាក់យាយ
គិតថាម៉ាក់យាយចូលចិត្តលេងដែរដូចជា លាក់កន្សែង ទាញព្រាត ចោលឈូង
បោះអង្គញចឹងហាស?

ខ៖  អត់មានទេ មិនដែរដើរលេងនឹងគេទេ

ក៖  អត់ដែរទេណម៉ាក់យាយ ប៉ុន្តែធ្លាប់តែមើលគេណម៉ាក់យាយ?

ខ៖  ទៅវត្តចឹងទៅ ចេះតែមើលគេចឹងទៅ

ក៖  អូ៎!បាទ ចុះម៉ាក់យាយចេះច្រៀងទេ?

ខ៖  អត់ចេះទេ

ក៖  ប៉ុន្តែម៉ាក់យាយចូលចិត្តមើលជាល្ខោន រឺជាអីមួយទេ?

ខ៖  ស្លាប់ហើយនៅស្រុកស្រែអូនអើយ ពីដើមនឹងមិនដឹងថាល្ខោនណា យីកេរ្តិ៍ណា អាយៃណា គុនណាទេអត់ចេះទេ មិនដែរមានទេនៅស្រុកស្រែនឹង

ក៖  បាទចឹងហោសម៉ាក់យាយ?

ខ៖  មានការលំបាកនឹងបានថាមានការលំបាកនឹង ធ្វើតែស្រែ ឃ្វាលតែគោ នោះទៅសប្បាយនៅតាមវាលស្រែហោស ឃ្វាលគោ ដេញចាប់គោ មកផ្ទះនឹងសប្បាយណាស់

ក៖ ចុះសំរាប់ម៉ាក់យាយមាននរណាគេម្នាក់នៅក្នុងផ្ទះរបស់ម៉ាក់យាយចេះលេងឧបករណ៍ភ្លេងទេ?

ខ៖  អត់មានទេ

ក៖  លក្ខណះជាភ្លេងខ្មែរ រឺមួយភ្លេងអាមេរិចអី ដូចជាហ្គីតាអីចឹងហាសម៉ាក់យាយ?

ខ៖  អត់ចេះទេ

ក៖  ចុះផ្ទះរបស់ម៉ាក់យាយតាំងពីក្មេងហាស មានលក្ខណះបែបណាដែរម៉ាក់យាយ កាលពីក្មេងផ្ទះយ៉ាងម៉េច ហើយឥឡូវនឹងផ្ទះយ៉ាងម៉េចចឹងហាស?

ខ៖  ពីដើមផ្ទះឈើ ប្រកស្លឹក

ក៖  តែដល់ពេលឥឡូវនឹងវិញ?

ខ៖  ដល់ពេលដែរប្រកស្លឹកហើយ មកប្រកស័ង្គសី ពេលដែរស័ង្គសីហើយផ្ទះថ្ម ពេលដែរផ្ទះថ្មហើយក៏ត្រលប់មកផ្ទះស័ង្គសីវិញទៀតនឹង

ក៖  អូ៎!ម៉េចចឹងម៉ាក់យាយ?

ខ៖  ចុះអាពតចូលមកវាមិនអត់

ក៖  ប៉ុន្តែម៉ាក់យាយមានចងចាំថាម៉ាក់យាយជូលគេ រឺមួយម៉ាក់យាយធ្វើខ្លួនឯងដែរគិតថាជាអ្នកសាងសងចឹងហាស?

ខ៖  ជួលជាង

កៈ អូ!ម៉ាក់យាយជួលជាងហោសម៉ាក់យាយ?

ខៈ នៅស្រុកស្រែមិនបាច់ជួលគេទេអូន ដាំតែបាយអោយគេហូបនឹងទៅបានហើយនឹង

កៈ ប៉ុន្តែអត់មាននរណាគេនៅក្នុងក្រុមគ្រួសារម៉ាក់យាយចេះធ្វើផ្ទះទេណាម៉ាក់យាយ?

ខៈ អត់មានទេ

កៈ
ចុះម៉ាក់យាយគិតថាម៉ាក់យាយចេះជំនាញអីដែរម៉ាក់យាយគិតថាម៉ាក់យាយអាចធ្វើបានចឹងហាស?

ខៈ ចេះធ្វើនុំបញ្ចុក

កៈ អូ!ចេះធ្វើនុំបញ្ចុកហោសម៉ាក់យាយ?

ខៈ នឹងហើយចេះធ្វើ

កៈ ចុះឪពុកម្តាយរបស់ម៉ាក់យាយធ្លាប់បានបង្រៀនពីជំនាញអីទៅម៉ាក់យាយទេ
ដូចជាកូរស្ករ វេញវល្លិ៍ រឺមួយធ្វើផ្តៅ រឺធ្វើកន្ទេលអញ្ចឹតអីចឹងហាស?

ខៈ កូរស្ករនឹងដូចជាការធម្មតាទេ

កៈ ម៉ាក់យាយចេះហោស?

ខៈ ចុះយើងអ្នកស្រែនឹងមានអី មានតែកូរស្ករ ធ្វើស្រែនឹង

កៈ ប៉ុន្តែម្តាយឪពុកជាអ្នកបង្រៀនហោសម៉ាក់យាយ?

ខៈ ចាំ!នឹងហើយ

កៈ ចុះម៉ាក់យាយគិតថាពេលណាដែរ
ម៉ាក់យាយគិតថាជាពេលដែរលំបាករបស់ម៉ាក់យាយដែរទេ?

ខៈ ជំនាន់ពលពតនឹង

កៈ ជំនាន់ពលពតហោសពិបាកខ្លាំងហោសម៉ាក់យាយ?

ខៈ ពិបាកណាស់

កៈ ដូចជាគេអោយម៉ាក់យាយធ្វើអីគេខ្លះដែរទៅម៉ាក់យាយ?

ខៈ ហូបបបរ ធ្វើស្រែនឹង

កៈ ប៉ុន្តែម៉ាក់យាយគេជំលាសម៉ាក់យាយទៅណាទៅ?

ខៈ ជំលាសនឹង ជំលាសរាប់មិនអស់ទេ

កៈ ដូចជាគេងោយម៉ាក់យាយទៅខេត្តណាដែរទៅម៉ាក់យាយ?

ខៈ ចេញពីខេត្តពោសាត់ទៅខេត្តបាត់ដំបង ទៅម៉ង់ទៅ
ទៅតាមព្រៃចឹងទៅមិនដឹងទៅណាខ្លះទេ យើងចេះតែទៅនឹង
គេអោយយើងទៅណាយើងចេះតែទៅនឹងហាស

កៈ ប៉ុន្តែម៉ាក់យាយធ្វើអីគេពេលណុងហាស?

ខៈ ធ្វើស្រែនឹងហាស

កៈ ធ្វើស្រែហោស គេអោយធ្វើតែស្រែទេហោសម៉ាក់យាយ?

ខៈ គេអោយទៅស្ទូង ទៅដក

កៈ អូ!ចុះរបបអាហារវិញម៉ាក់យាយ?

ខៈ មានបបរ

កៈ ចុះម៉ាក់យាយទៅម្នាក់ឯង រឺមួយទៅជាមួយក្រុមគ្រួសារដែរម៉ាក់យាយ?

ខៈ ក្រុមគ្រួសារនឹងនៅមួយកន្លែងចឹងទៅ យើងទៅចេះតែទៅនឹង ធ្វើរួមមកផ្ទះ
រឺមកខ្ទមវិញចឹងទៅណាស់

កៈ ចុះបងប្អូនរបស់ម៉ាក់យាយពេលណុងគេជំលាសទៅណាដែរទៅម៉ាក់យាយ?

ខៈ ទៅដូចតែគ្នានឹង ចេញទៅ

កៈ ប៉ុន្តែទៅខេត្តខុសពីយើង?

ខៈ អត់ទេនៅខេត្តមួយនឹង ប៉ុន្តែអ្នកខ្លះទៅកងព្រលិតទៅ ខ្លះក៏ទៅខាងស្រែទៅណាស់
ខ្លះក៏ជួយធ្វើចំការគេដាំនេះ ដាំនោះអីចឹងហាស

កៈ បាទម៉ាក់យាយ
ចុះពេលណុងឪពុកម្តាយរបស់ម៉ាក់យាយគេអោយទៅណាទៅម៉ាក់យាយ?

ខៈ គាត់ស្លាប់បាត់អស់ហើយនឹង

កៈ អូ៎!គាត់ស្លាប់មុននឹងពលពតចូលហោសម៉ាក់យាយ?

ខៈ នៅតែម្តាយទេ

កៈ អូ៎!ប៉ុន្តែម្តាយគេអោយទៅធ្វើនៅណាដែរទៅម៉ាក់យាយ?

ខៈ គាត់អោយមើលចៅ

កៈ អូ៎!អោយគាត់មើលចៅហោសម៉ាក់យាយ?

ខៈ ចា៎! មើលចៅកូនគេមួយហ្វូងចឹងទៅហាស

កៈ ចុះមុនជំនាន់ពលពតទៀតហាស ជំនាន់អឺសារ៉ាក់មែនទេម៉ាក់យាយ?

ខៈ ជំនាន់អឺសារ៉ាក់នឹងចេះតែខ្លាចទៅរត់ពួនទៅ

កៈ ចុះជំនាន់អឺសារ៉ាក់ គេអោយធ្វើអីទៅ?

ខៈ ខ្ញុំអត់ដឹងទេ ដឹងតែគេរត់ចូលត្រង់សេតែម្តងនឹងហាស

កៈ ប៉ុន្តែដូចជាជំនាន់ណុងដូចជាបារាំងជាអ្នកកាន់កាប់ហោសម៉ាក់យាយ?

ខៈ អឺសារ៉ាក់ចូល បារាំងចេញហើយនឹង

កៈ អូ៎!ចឹងមានន័យថា បារាំងចេញទៅអឺសារ៉ាក់ចូលមក?

ខៈ ចា៎! អឺសារ៉ាក់ ហើយបានជប៉ុនចូល

កៈ ហើយជប៉ុនហោស ចឹងពេលដែរជប៉ុនចូលមកគេអោយធ្វើអីដែរម៉ាក់យាយ?

ខៈ អត់ដឹងដែរនឹង

កៈ ប៉ុន្តែគ្រាន់តែពេលណុងដឹងតែមានសង្គ្រាម?

ខៈ មិនដឹងច្បាស់ទេ ពីព្រោះយើងនៅតូចនឹង

កៈ ប៉ុន្តែម៉ាក់យាយនៅណាដែរម៉ាក់យាយ?

ខៈ នៅខេត្តពោសាត់នឹង

កៈ ចឹងនៅពោសាត់រហូតហោសម៉ាក់យាយ?

ខៈ នឹងហើយនៅពោសាត់នឹង

កៈ ចុះពេលណាដែរម៉ាក់យាយមកនៅភ្នំពេញម៉ាក់យាយ?

ខៈ ពេលដែរដាច់ពលពតហើយនឹង

កៈ អូ៎!ពេលដែរបែកពលពតហោស
ចឹងមានន័យថាពេលដែរបែកពលពតភ្លាមហើយម៉ាក់យាយមកនៅភ្នំពេញវិញ?

ខៈ ចា៎!នឹងហើយ

កៈ ចុះម៉ាក់យាយបានធ្វើអីគេទៅពេលណុងដែរ?

ខៈ គ្មានបានធ្វើអីទេ លក់ដូរបន្តិចបន្តួចនឹង ចិញ្ចឹមកូនដើររើសអេតចាយចឹងទៅ

កៈ ប៉ុន្តែពេលណុងម៉ាក់យាយ មានក្រុមគ្រួសារហើយមែនទេម៉ាក់យាយ?

ខៈ មានហើយ

កៈ ចុះម៉ាក់យាយមានតាំងពីមុនពលពត រឺក៏ពលពតហើយ?

ខៈ មានមុនពលពត

កៈ មុនពលពត ចុះពេលណុងម៉ាក់យាយ មានកូនហើយនៅពេលដែរពលពតហាស?

ខៈ ខ្ញុំមានកូនមួយ

កៈ ចឹងពេលដែរម៉ាក់យាយមានកូនចឹងគេអោយម៉ាក់យាយធ្វើអីគេទៅ?

ខៈ អោយយើងទៅធ្វើស្រែនឹង

កៈ ចុះកូនៗហោសម៉ាក់យាយ?

ខៈ កូនៗតូចនឹង ហើយយើងទៅធ្វើស្រែទៀតទៅ

កៈ ប៉ុន្តែកូនគេអោយនៅផ្ទះ?

ខៈ កូនគេអោយយាយចិញ្ចឹម

កៈ ចឹងយាយៗជាអ្នកមើលកូនម៉ាក់យាយវិញ?

ខៈ នឹងហើយ

កៈ ចឹងសំរាប់ដាច់ពលពតមកម៉ាក់យាយទៅណា?

ខៈ ចេះតែនាំកូនៗនឹងនាំប្តីដើរមក មកនៅនឹង

កៈ អូ្ន!ម៉ាក់យាយមកនៅនឹងតែម្តងហោសម៉ាក់យាយ?

ខៈ ចា៎!នៅនឹង

កៈ អត់មានផ្លាស់ទៅនៅណាផ្សេងសិនទេហោសម៉ាក់យាយ?

ខៈ អត់មានទេ

កៈ រហូតដល់ជីវិភាពរបស់ម៉ាក់យាយមានរៀងធូរម្តងបន្តិចៗ?

ខៈ នឹងហើយវាចឹង

កៈ រហូតមកដល់ឥឡូវនឹងហោសម៉ាក់?

ខៈ មានតែចឹង

កៈ ចុះម៉ាក់យាយឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរម៉ាក់យាយ តាំងពីជំនាន់ពលពតរឺមួយក៏ជំនាន់មុនពលពតអីចឹងហាស រហូតមកដល់ឥឡូវនឹងហាស ម៉ាក់យាយឆ្លងដោយវិធីណាដែរ?

ខៈ ទេការធម្មតាយើងចាស់ពីដើម ប៉ុណ្ណឹងគេមិនថាពិបាកទេគ្រាន់តែនឿយហាត់ គ្រាន់តែស៊ីមួយចំអែតកាយយើងគេថាមិនហាត់ទេនឹងហាស មិនដូចគេអ្នករកស៊ីមានបានទេលក្ខណៈយើងមួយចំអែតខ្លួននឹង លក្ខណៈធម្មតាៗទេប៉ុន្តែវាពិបាកដែរ

កៈ ចឹងហោសម៉ាក់យាយ?

ខ៖ វាពិបាកពេលដែរយើងជិតអស់ហូបហាស

ក៖ បាទម៉ាក់យាយ
ចុះម៉ាក់យាយគិតថាពេលណាដែរម៉ាក់យាយគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់ម៉ាក់យាយហាស?

ខ៖ ធម្មតាៗនឹង

ក៖ ចុះពេលដែរម៉ាក់យាយការ រឺមួយពេលដែរការកូនអីចឹង
រឺមួយមានចៅៗអីដែរធ្វើអោយម៉ាក់យាយសប្បាយចិត្តហាស?

ខ៖ នឹងហើយបានមានចៅទៅគ្រាន់បានប្រលែងលេងជាមួយចៅចឹងទៅ

ក៖ នឹងជាពេលដែរសប្បាយ
រឺមួយក៏ជួបជុំដែរគ្នាដែរធ្វើអោយម៉ាក់យាយសប្បាយដែរទាំងអស់គ្នាចឹងទៅណាម៉ាក់យាយ?

ខ៖ នឹងសប្បាយ

ក៖ ចុះម៉ាក់យាយកាលពីក្មេងហាស
តើម៉ាក់យាយធ្លាប់មានក្តីស្រម៉ៃថាពេលដែរធំឡើងថាមានក្តីស្រម៉ៃអីទេ?

ខ៖ អត់មានទេ

ក៖ អត់ធ្លាប់មានទេណាម៉ាក់យាយ
ចុះពេលដែរនៅរៀនហាសម៉ាក់យាយធ្លាប់មានគិតថាម៉ាក់យាយចង់ធ្វើជាពេទ្យ
រឺធ្វើជាទាហ៊ាន រឺធ្វើជាគ្រូបង្រៀនអីទេ?

ខ៖ អត់ចេះអក្សរផងមានអីរៀនទៅ

ក៖ អ្ហូ!ម៉ាក់យាយអត់បានរៀនទេណា ខ្ញុំភ្លេច

ខ៖ ប្រាប់ថាអត់បានរៀនហើយនឹងហាស

ក៖ ចុះម៉ាក់យាយ ចង់អោយផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗហាស
តើម៉ាក់យាយចង់ផ្តែផ្តាំអីទៅពួកគាត់ដែរម៉ាក់យាយ?

ខ៖ ចង់អោយកូនក្រោយៗអោយចងចាំ កាលលំបាកពលពតវានឿយខ្លាំងណាស់ វាពិបាកខ្លាំងណាស់ ហើយក៏វាជិតស្លាប់អស់ខ្លាំងណាស់ដែរនឹង ត្រូវចងចាំកុំអោយប្រហែស

ក៖ មានអីចង់ផ្ដែផ្ដាំដើម្បីអោយពួកគាត់អាចដូចជាងោយដើរកន្លងផ្លូវធិមល្អចឹងហាស?

ខ៖ នឹងហើយចង់អោយចឹង

ក៖ ដូចជាអោយពួកគាត់មានការងារល្អអីចឹងហាស?

ខ៖ នឹងត្រូវហើយនឹងហាស ត្រូវចងចាំកុំអោយភ្លេច អោយទៅតាមផ្លូវ កន្លងល្អ កុំអោយទៅតាមផ្លូវអាក្រក់អី កុំចង់បានទ្រព្យគេពេក នឹងគេញប្រវ៉ាញ់ទ្រព្យសម្បត្តិគេ រកស៊ីតាមសមត្ថភាព

ក៖ បាទចុះអ្វីដែរផ្សេងទៀតដែរម៉ាក់យាយចង់អោយគាត់ជៀសហាស ចង់អោយពួកគាត់ជៀសផុតពីអីគេវិញម៉ាក់យាយ លក្ខណះអោយពួកគាត់ជៀសផុតពីជក់គ្រឿងញៀនរឺមួយអីចឹងហាស?

ខ៖ អូ!អានឹងហួសណាស់ទៅហើយ ហួសតែម្ដងនឹងមិនថាអោយគាត់ជៀសទេ យើងវៃថៃមទៀតនឹងហាស

ក៖ ចឹងហោសម៉ាក់យាយ?

ខ៖ ខ្ញុំមិនចូលចិត្ត ពីព្រោះយើងមនុស្សចាស់ចឹងយើងមិនចូលចិត្តទេ

ក៖ បាទត្រូវហើយម៉ាក់យាយ?

ខ៖ កូនចៅរបស់ខ្ញុំគ្មានមានទេចឹងៗហោស

ក៖ បាទមានអីចង់ផ្ដែផ្ដាំទៀតទេម៉ាក់យាយ?

ខ៖ អស់ហើយកូន

ក៖ ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនម៉ាក់យាយដែរបានអោយខ្ញុំ ដូចជាផ្ដល់ពេលវេលាពិភាក្សាអោយខ្ញុំបានសំភាសន៍ពីប្រវត្តិរបស់ម៉ាក់យាយ ហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលា អំពីប្រវត្តិរបស់ម៉ាក់យាយចឹងហាស

ខ៖ អ្នកស្រែសុទ្ធហើយនេះប្រាប់គាត់ទៅ

ក៖ អ្នកស្រែសុទ្ធហោសម៉ាក់យាយ?

ខ៖ អ្នកស្រែតែម្តងនឹង

ក៖ អត់ទេម៉ាក់យាយមកនៅភ្នំពេញយូរហើយចឹងក្លាយជាអ្នកភ្នំពេញហើយ

ខ៖ ខ្ញុំជាអ្នកស្រែទេ បើមិនទៅធ្វើស្រែបានអីញ៉ាំ

ក៖ ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនម៉ាក់យាយដែរបានអោយខ្ញុំសំភាសន៍ពីម៉ាក់យាយ
ចឹងខ្ញុំជូនពរម៉ាក់យាយអោយមានសុខភាពល្អ ហើយនឹងអាយុវែងចឹងហាស
ហើយនឹងចង់អោយកូនចៅធ្វើតាមនូវអ្វីដែរម៉ាក់យាយបានផ្តែផ្តាំទៅពួកគាត់ដែរចឹងហាស
អ្វីដែរម៉ាក់យាយផ្តែផ្តាំនៅក្នុងនឹងចឹងហាសម៉ាក់យាយ

ខ៖ ចា៎!ល្អ សាធុ សាធុ

ក៖ បាទអរគុណច្រើនម៉ាក់យាយ៕៕៕